ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...០..៣../ប.ក

# សេចក្តីប្រកាស

## របស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា

កៅស៊ូធម្មជាតិ គឺជាដំណាំកសិ-ឧស្សាហកម្ម ដែលបានផ្តល់ផលប្រយោជន៍យ៉ាងសំខាន់សំរាប់សេដ្ឋកិច្ចជាតិ ។ ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានស្រូបយករូបិយប័ណ្ណយ៉ាងច្រើនដែលបានមកពីការនាំចេញផលិតផលកៅស៊ូធម្មជាតិ ។

ប្រទេសកម្ពុជាមានដីក្រហម និងដីប្រភេទផ្សេងៗទៀតរាប់សែនហិកតាដែលមានសក្តានុពលអាចដាំដុះកៅស៊ូបាន ប៉ុន្តែរហូតទល់បច្ចុប្បន្ននេះ យើងនៅពុំទាន់បានប្រើប្រាស់ឱ្យអស់សក្តានុពលនេះនៅឡើយ ។

ការដាំដុះកៅស៊ូឡើងវិញស្ថិតនៅក្នុងស្ថានភាពមួយយឺតយ៉ាវ និងមិនទាន់សមស្របតាមសភាពការណ៍នៃការអភិវឌ្ឍន៍ដំណាំកៅស៊ូនៅទូទាំងប្រទេសនៅឡើយ ។

ថ្វីត្បិតតែក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ និន្នាការនៃតម្លៃកៅស៊ូធម្មជាតិនៅលើទីផ្សារអន្តរជាតិបានធ្លាក់ចុះយ៉ាងខ្លាំង ដែលមិនធ្លាប់មានសោះតាំងពីមុនមក តែតម្លៃកៅស៊ូនឹងងើបឡើងវិញនៅក្នុងអនាគតដ៏ខ្លីខាងមុខ ហើយដំណាំកៅស៊ូនៅតែរក្សាបាននូវនាទីមួយចំណែកយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចជាតិ ។

ដើម្បីឱ្យដំណាំកៅស៊ូមានការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សលើគ្រប់ផ្នែក ទាំងផ្នែកកសិ-ឧស្សាហកម្ម ទាំងផ្នែកឯកជន និងជាពិសេសផ្នែកដំណាំកៅស៊ូគ្រួសារ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់អាទិភាពខ្ពស់ដល់ដំណាំនេះ ដោយបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់ខ្លួនក្នុងអាណត្តិទី២ថា "រាជរដ្ឋាភិបាលនឹងលើកទឹកចិត្តដល់កសិករឱ្យដាំដំណាំកៅស៊ូនៅលើចំការតូចតាចរបស់ខ្លួនតាមគោលនយោបាយនៃការផ្តល់ឥណទាន ការផ្តល់សិទ្ធិលើការកាន់កាប់ និងការប្រើប្រាស់ដីធ្លីឱ្យបានសមស្រប" ។

គោលបំណងដ៏សំខាន់របស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារគឺសំដៅ :

- អភិវឌ្ឍន៍ដំណាំកៅស៊ូនៅកម្ពុជាឱ្យបានរីកចំរើនឆាប់រហ័ស ។/

- ជួយបង្កើនប្រភពប្រាក់ចំណូល ដែលបានមកពីការធ្វើអាជីវកម្មកៅស៊ូដល់កសិករ និងជួយកាត់បន្ថយភាពក្រីក្រនៅតាមជនបទ ។
- បង្កើនប្រភពប្រាក់ចំណូលដល់ខឿនសេដ្ឋកិច្ចជាតិតាមរយៈការនាំចេញផលិតផលកៅស៊ូ ។
- ជួយការពារបរិស្ថានទល់នឹងភាពហួតហែងក្តៅខ្លាំងនៃធម្មជាតិ និងការហូរច្រោះដី ។

គោលនយោបាយអភិវឌ្ឍន៍នេះ គឺសំដៅជួយកសិករតូចតាចឱ្យដាំដំណាំកៅស៊ូដែលមានទិន្នផលខ្ពស់ រួមទាំងដំណាំកសិផលផ្សេងៗទៀតនៅតាមចន្លោះរងកៅស៊ូ សំរាប់ធានាជីវភាពរស់នៅរបស់កសិកររហូតដល់រយៈពេលនៃការចាប់ផ្តើមចៀរជ័រកៅស៊ូ ។

កសិករដែលស្ម័គ្រចិត្តចូលរួមក្នុងគំរោងអភិវឌ្ឍន៍នេះ ត្រូវបានរាជរដ្ឋាភិបាលធានា និងលើកទឹកចិត្តដោយ :

- ផ្តល់ជូននូវសិទ្ធិក្នុងការកាន់កាប់ ការប្រើប្រាស់ដីចំការ ការបន្តមរតក ឬការផ្ទេរសិទ្ធិឱ្យអ្នកដទៃ ព្រមទាំងរដ្ឋធានាមិនធ្វើជាតូបនីយកម្មឡើយ ។
- សំរួលដល់ការខ្ចីឥណទានតាមរយៈធនាគារអភិវឌ្ឍន៍ជនបទតាមលក្ខខណ្ឌ និងវិធីសាស្ត្រនានាដែលមាន ។
- ផ្តល់ជូននូវការបណ្តុះបណ្តាល និងសេវាបច្ចេកទេសក្នុងការដាំដុះ ការថែទាំ រហូតដល់ការប្រមូលផល ព្រមទាំងផ្តល់ពត៌មានស្តីពីទីផ្សារផលិតផលកៅស៊ូ ។
- ផ្តល់នូវសិទ្ធិក្នុងការទទួលផលពីចំការរបស់ខ្លួន ការកែច្នៃ និងការលក់ដូរផលិតផលកៅស៊ូដោយសេរី ។
- កសិករមានសិទ្ធិរៀបចំសមាគមកសិករដាំកៅស៊ូ សំរាប់ការពារផលប្រយោជន៍របស់សមាជិកម្នាក់ៗ ។

រាជរដ្ឋាភិបាលសង្ឃឹមថា ប្រជាកសិករនៅទូទាំងប្រទេសនឹងចូលរួមយ៉ាងសកម្មនៅក្នុងការដាំដុះកៅស៊ូជាលក្ខណៈគ្រួសារ សំរាប់លើកស្ទួយសេដ្ឋកិច្ចជាតិ និងជីវភាពរស់នៅរបស់ខ្លួនប្រកបដោយសុភមង្គល ។

ទទួលបានសេចក្តីប្រកាសនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មការតាមដាន និងជំរុញការអនុវត្តន៍គំរោងអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារ ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងខិតខំអនុវត្តការងារនេះ ដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធិភាពខ្ពស់ ព្រមទាំងរាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលសំរេចបាន និងបញ្ហានានាដែលកើតឡើង ដើម្បីមានវិធានការណ៍ជាក់ស្តែង ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ក្រសួង - ស្ថាប័ន
- គ្រប់សាលាខេត្តក្រុង
- ឯកសារ-កាលប្បវត្តិ

លេខ : ៦៨០ អក

ពិនិត្យមើលត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃទី ... ខែសីហា ឆ្នាំ២០០០

... នៃគណៈនាយកដ្ឋានចំការកៅស៊ូ

លី_ផល្លា